# និយ័តករគណនេយ្យនិងសវនកម្ម

## ព្រឹត្តិបត្រព័ត៌មានប្រចាំខែកក្កដា ឆ្នាំ២០២៤

លេខ:០០៧


សេចក្ដីសង្ខេបព័ត៌មាន និងព្រឹត្តិការណ៍សំខាន់ៗប្រចាំខែកក្កដា របស់និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគាររួមមានដូចខាងក្រោម៖

## កិច្ចប្រជុំក្រុមប្រឹក្សា នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ លើកទី១៩ នៃអាណត្តិទី១




១.កាលពីថ្ងៃអង្គារ ១១ រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹង ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤ តាមប្រព័ន្ធអនឡាញ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម ក្នុងនាមជាសមាជិកក្រុមប្រឹក្សា អ.ស.ហ. បានអញ្ជើញចូលរួម កិច្ចប្រជុំក្រុមប្រឹក្សា នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ លើកទី១៩ នៃអាណត្តិទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** និងមានការចូលរួមពី ឯកឧត្តម លោកជំទាវ ជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សានៃ អ.ស.ហ. ។ ក្នុងរបៀបវារៈនៃកិច្ច ប្រជុំចំនួន៤ ក្នុងនោះក៏មានការពិភាក្សានិងផ្ដល់យោបល់លើសេចក្ដីព្រាងយុទ្ធសាស្ត្រ អភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្ម នៅកម្ពុជា ( ២០២១-២០៣០) ។

## កិច្ចពិភាក្សាជាមួយ ឯកឧត្តមបណ្ឌិត ជួប ប៉ារីស៍ រដ្ឋលេខា ធិការក្រសួងបរិស្ថាន



## ព័ត៌មានថ្មីៗ


កិច្ចប្រជុំក្រុមប្រឹក្សា សូមអាននៅទំព័រ.......១
កិច្ចពិភាក្សា សូមអាននៅទំព័រ ..................២
កិច្ចប្រជុំពិនិត្យ សូមអាននៅទំព័រ .............២
កិច្ចប្រជុំវឌ្ឍនភាព សូមអាននៅទំព័រ........២
កិច្ចពិភាក្សា សូមអាននៅទំព័រ...................៣
កម្មវិធីចុះហត្ថលេខាសូមអាននៅទំព័រ.....៣
កិច្ចប្រជុំបច្ចេកទេស សូមអាននៅទំព័រ....៤
កិច្ចប្រជុំបច្ចេកទេស សូមអាននៅទំព័រ....៤
សិក្ខាសាលា(គ.ស.ក.) សូមអាននៅទំព័រ...........................................................................៥
កិច្ចប្រជុំលើកទី១០ សូមអាននៅទំព័រ.............................................................................៥
វគ្គបណ្ដុះបណ្ដាល សូមអាននៅទំព័រ..............................................................................៦
វេទិកាផ្សព្វផ្សាយ សូមអាននៅទំព័រ..............................................................................៦
កិច្ចប្រជុំស្ដីពី សូមអាននៅទំព័រ...................៧
សិក្ខាសាលា សូមអាននៅទំព័រ..................៧
វគ្គបណ្ដុះបណ្ដាល សូមអាននៅទំព័រ.........៨
កិច្ចប្រជុំ សូមអាននៅទំព័រ...........................៨
សិក្ខាសាលា សូមអាននៅទំព័រ..................៩
កិច្ចប្រជុំ សូមអាននៅទំព័រ.........................៩
ការប្រឡង សូមអាននៅទំព័រ..................១០
សិក្ខាសាលា សូមអាននៅទំព័រ...............១០
វគ្គបណ្ដុះបណ្ដាល សូមអាននៅទំព័រ......១១
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ.........១១
កិច្ចប្រជុំ សូមអាននៅទំព័រ.......................១២
វគ្គបណ្ដុះបណ្ដាល សូមអាននៅទំព័រ......១២
កម្មវិធីចុះអនុស្សរណៈ សូមអាននៅទំព័រ...........................................................................១៣
កិច្ចប្រជុំ សូមអាននៅទំព័រ.......................១៤


© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

២.កាលពីថ្ងៃចន្ទ ១០រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤ នៅទីស្តីការក្រសួងបរិស្ថាន **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង បានដឹកនាំមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេស ចូលជួបពិភាក្សាជាមួយ **ឯកឧត្តមបណ្ឌិត ជួប ប៉ារីស៍** រដ្ឋលេខាធិការក្រសួងបរិស្ថាន ដើម្បីសិក្សាស្វែងយល់បន្ថែមអំពីការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្រ្ត ក្របខណ្ឌគតិយុត្តិ ដែលពាក់ព័ន្ធនឹងការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍដោយចីរភាព។

## កិច្ចប្រជុំពិនិត្យមើលលើឯកសារការងារនិងតារាងក្រុមហ៊ុនសវនកម្ម




៣.កាលពីថ្ងៃពុធ ១២ រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៤ នៅបន្ទប់ប្រជុំធំនៃនិយ័តករគណនេយ្យនិងសវនកម្ម **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក ជេន ផាត** អគ្គនាយករង បានដឹកនាំកិច្ចប្រជុំស្តីពីការជ្រើសរើសក្រុមហ៊ុនសវនកម្មដើម្បីធ្វើការចុះត្រួតពិនិត្យគុណភាពសវនកម្មឆ្នាំ២០២៤ និងវឌ្ឍនភាពនៃផែនការដែលបានគ្រោងទុក។ កិច្ចប្រជុំនេះមានគោលបំណងពិនិត្យមើលលើឯកសារការងារដែលមន្ត្រីជំនាញបានរៀបចំ និងតារាងក្រុមហ៊ុនសវនកម្មទាំងមានការទទួលខុសត្រូវជាសាធារណៈ (PIE) និងមិនមានការទទួលខុសត្រូវជាសាធារណៈ (Non-PIE)។

## កិច្ចប្រជុំវឌ្ឍនភាពការងារក្នុងការរៀបចំវេទិកាគណនេយ្យជាតិឆ្នាំ២០២៤




៤.កាលពីថ្ងៃពុធ ១២រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៤ ក្រោមការដឹកនាំរបស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំកិច្ចប្រជុំក្រុមការងារបង្គោលដើម្បីពិនិត្យវឌ្ឍនភាពការងារមួយចំនួនក្នុងការរៀបចំវេទិកាគណនេយ្យជាតិឆ្នាំ២០២៤ ក្រោមប្រធានបទ “តួនាទី នៃគណនេយ្យនិងបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាសម្រាប់ចក្ខុវិស័យឆ្នាំ២០៣០” ដោយមានការចូលរួមពី លោក លោកស្រី អគ្គនាយករង នៃ ន.គ.ស. វិទ្យាស្ថានគណនេយ្យករ

ជំនាញនិងសវនករកម្ពុជា ACCA ប្រចាំប្រទេសកម្ពុជា ព្រមទាំងកិច្ចសហការគាំទ្រពីក្រុមហ៊ុន DFC ក្រុមហ៊ុន Banhji និងក្រុមការងាររបស់ ន.គ.ស.។

## កិច្ចពិភាក្សាស្តីពី “សក្តានុពលនៃយន្តការបរធនបាលកិច្ចនិងនិន្នាការថ្មីៗនៃសេដ្ឋកិច្ច និងបច្ចេកវិទ្យា”



៥.កាលពីថ្ងៃពុធ ១១ រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៤ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី ថោ សេដ្ឋចាន់លីដា** អនុប្រធាននាយកដ្ឋាន បានអញ្ជើញចូលរួមកម្មវិធីបាឋកថាស្តីពី “បច្ចុប្បន្នភាពនៃម៉ាក្រូសេដ្ឋកិច្ចកម្ពុជា” និងកម្មវិធីកិច្ចពិភាក្សាស្តីពី “សក្តានុពលនៃយន្តការបរធនបាលកិច្ចនិងនិន្នាការថ្មីៗនៃសេដ្ឋកិច្ចនិងបច្ចេកវិទ្យា” ដែលរៀបចំដោយនិយ័តករបរធនបាលកិច្ចនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## កម្មវិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករអាជីវកម្ម អចលនវត្ថុ និងបញ្ចាំ និងវិទ្យាស្ថានហិរញ្ញវត្ថុនិងគណនេយ្យ



៦.កាលពីថ្ងៃព្រហស្បតិ៍ ១៣រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤ នៅសាលប្រជុំជាន់ទី២ នៃអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ណុប សម្បត្តិ** អនុប្រធាននាយកដ្ឋាន អមដោយមន្ត្រីជំនាញនៃនាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម បានអញ្ជើញចូលរួមកម្មវិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករអាជីវកម្មអចលនវត្ថុ និង

បញ្ញាំ និងវិទ្យាស្ថានហិរញ្ញវត្ថុនិងគណនេយ្យស្តីពី “កិច្ចសហប្រតិបត្តិការដើម្បីលើកកម្ពស់ការយល់ដឹងអំពីវិស័យអចលនវត្ថុ វិស័យបញ្ញាំ និងប្រាតិភាគដោយអនុប្បទាននៅកម្ពុជា”។

## កិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទ អ.ស.ហ.



៧.កាលពីថ្ងៃព្រហស្បតិ៍ ១៣ រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤ តាមរយៈប្រព័ន្ធអនឡាញ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញ នៃ ន.គ.ស. បានចូលរួមកិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទ អ.ស.ហ. ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីពិនិត្យនិងផ្តល់យោបល់ទៅលើបទប្បញ្ញត្តិរួមមាន៖ ១.សេចក្តីព្រាងអនុក្រឹត្យស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ២.សេចក្តីព្រាងប្រកាសស្តីពីការដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ។

## កិច្ចប្រជុំបច្ចេកទេសអង្គភាពក្រោមឱវាទ អ.ស.ហ.




៨.កាលពីថ្ងៃសុក្រ ១៤ រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤ បន្ទប់ប្រជុំធំនិយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមថ្នាក់ដឹកនាំ

និងមន្ត្រីជំនាញ នៃ ន.គ.ស. លើ “សេចក្តីព្រាងអនុក្រឹត្យស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពី គណនេយ្យ និងសវនកម្ម” និង “សេចក្តីព្រាងប្រកាសស្តីពីការដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ” ដើម្បីពិនិត្យពិភាក្សានិងផ្តល់អនុសាសន៍លើការងារបន្តនៃសេចក្តីព្រាងខាងលើឱ្យស្របតាមស្មារតី នៃកិច្ចប្រជុំបច្ចេកទេសអង្គភាពក្រោមឱវាទ អ.ស.ហ. ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ កាលពីថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤។

## សិក្ខាសាលាស្តីពីកាតព្វកិច្ចគណនេយ្យនិងសវនកម្ម សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញរបស់(គ.ស.ក.)



៩.កាលពីព្រហស្បតិ៍ ៦កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤ នៅភោជនីយដ្ឋានទន្លេបាសាក់២ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម បានអញ្ជើញថ្លែងសុន្ទរកថាបើក សិក្ខាសាលាស្តីពីកាតព្វកិច្ចគណនេយ្យនិងសវនកម្ម សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ រៀបចំឡើងដោយគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា។ សិក្ខាសាលានេះ មានការចូលរួមពីមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម និងសិក្ខាកាមដែលជាតំណាងមកពីអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលមានអ្នកចូលរួមប្រមាណជាង២០០នាក់។

## កិច្ចប្រជុំ “ លើកទី១០ របស់គណៈកម្មាធិការត្រួតពិនិត្យនៃកម្ពុជា”




១០.កាលពីថ្ងៃព្រហស្បតិ៍ ៦ កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាប្រធានគណៈកម្មាធិការត្រួតពិនិត្យនៃកម្ពុជា បានដឹកនាំកិច្ចប្រជុំ “ លើកទី១០ របស់គណៈកម្មាធិការត្រួតពិនិត្យនៃកម្ពុជា” ដែលមានការអញ្ជើញចូលរួមដោយ **លោកស្រី ហង្ស សូផាតម៉ូលីហ្សាណា** អនុប្រធាន

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

និងលោក លោកស្រី សមាជិក ព្រមទាំងលេខាធិការដ្ឋាននៃគណៈកម្មាធិការត្រួតពិនិត្យនៃកម្ពុជា តាមប្រព័ន្ធអនឡាញ ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖ ១. ពិនិត្យ និងវាយតម្លៃបុគ្គលស្នើសុំចុះឈ្មោះជាគណនេយ្យករជំនាញអាស៊ាន ចំនួន៥រូប បន្ថែមទៀតគឺ (លោក ហេង គិតសុផលលោក តាំង សុទី លោក សាយ សុខខេង, លោក ខាវ ហុង, និងលោកស្រី ឡួន ស៊ីនរតនា)។ ២.របាយការណ៍អំពីលទ្ធផលកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលគណនេយ្យករជំនាញអាស៊ានលើកទី២៤ នៅខេត្តសៀមរាប កាលពីថ្ងៃទី៤-៧ ខែមិថុនា ឆ្នាំ២០២៤។ ក្នុងនោះផងដែរអង្គប្រជុំបានឯកភាពជាគោលការនឹងត្រៀមបន្តនីតិវិធីបញ្ជូនឈ្មោះបេក្ខជនទាំង៥រូប ជូនលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលគណនេយ្យករជំនាញអាស៊ាន ដើម្បីពិនិត្យ និងអនុញ្ញាតចុះឈ្មោះបេក្ខជនទាំងនោះជាគណនេយ្យករជំនាញអាស៊ាន។

## វគ្គបណ្តុះបណ្តាលស្តីពី "កម្មវិធីត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ-Financial Statements Review Program"




១១.កាលពីថ្ងៃពុធ ៥កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី**ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី នាន បូនី** អគ្គនាយករង នៃ ន.គ.ស. អមដោយ **លោក លី កុសល** អនុប្រធានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្ត និងអនុលោមភាព បានដឹកនាំមន្ត្រីជំនាញចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "កម្មវិធីត្រួតពិនិត្យរបាយការណ៍ ហិរញ្ញវត្ថុ-Financial Statements Review Program" នៅស្ថានប័ន TYMBA សហការជាមួយក្រុមហ៊ុន DFC និងទស្សនកិច្ចសិក្សានៅវិទ្យាស្ថានគណនេយ្យករម៉ាឡេស៊ី ( MIA )ដើម្បីកសាងសមត្ថភាពមន្ត្រីជំនាញដូចដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍ស្ថាប័ន រយៈពេល៥ឆ្នាំ (២០២១-២០២៥) របស់ ន.គ.ស.។ ប្រធានបទសំខាន់ៗនៃវគ្គបណ្តុះបណ្តាលនេះរួមមាន៖ ១. ការរៀបចំផែនការត្រួតពិនិត្យ។ ២. វិធីសាស្ត្រនៃការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស្តង់ដាគណនេយ្យ។ ៣. ការវាយតម្លៃនិងការរាយការណ៍អំពីលទ្ធផលនៃការត្រួតពិនិត្យ។ ៤. ការត្រួតពិនិត្យលើឯកសារ។

## វេទិកាផ្សព្វផ្សាយស្តីពី “នីតិវិធីក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមប្រព័ន្ធអនឡាញ (E-Filing)”




១២.កាលពីថ្ងៃអង្គារ ១១កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤ **និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** បានរៀបចំវេទិកាផ្សព្វផ្សាយស្តីពី **“នីតិវិធីក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមប្រព័ន្ធអនឡាញ (E-Filing)”**សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញតាមប្រព័ន្ធអនឡាញ (zoom) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព និងមានការអញ្ជើញ

ចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងវត្តមានរបស់តំណាងសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញសរុបចំនួន ៤៤០នាក់។ វេទិកានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយ ជូនដល់នាយកក្រុមហ៊ុន តំណាងក្រុមហ៊ុន សហគ្រាស តំណាងមកពីអង្គការសមាគមនានាបានស្វែងយល់ និងចូលរួមអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមប្រព័ន្ធអនឡាញ (E-Filing) មកនិយ័តករគណនេយ្យនិងសវនកម្ម តាមពេលកំណត់ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធព្រមទាំងប្រកបទៅដោយប្រសិទ្ធភាពខ្ពស់។

## កិច្ចប្រជុំស្តីពី ការបូកសរុបវឌ្ឍនភាពការងារប្រចាំឆមាសទី១ ឆ្នាំ២០២៤



១៣.កាលពីថ្ងៃ ព្រហស្បតិ៍ ១៣កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំកិច្ចប្រជុំស្តីពី ការបូកសរុបវឌ្ឍនភាពការងារប្រចាំឆមាសទី១ ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ លោក- លោកស្រី អគ្គនាយករង និងមានការអញ្ជើញចូលរួមពីលោក លោកស្រី អនុប្រធាននាយកដ្ឋាន និងមន្ត្រីក្រោមឱវាទទាំងអស់ នៃ និយ័តករគណនេយ្យនិងសវនកម្ម។

## សិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការកំណត់ប្រភេទហានិភ័យនៃវិស័យហិរញ្ញវត្ថុមិនមែន



១៤.កាលពីថ្ងៃព្រហស្បតិ៍ ១៣ កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤ ដោយទទួលបានការចាត់តាំងដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី អេង រ័ត្នធដា** និង **លោក លឹម ចាន់រតនៈ** បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការកំណត់ប្រភេទហានិភ័យនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមអធិបតីភាពរបស់ **លោកបណ្ឌិត សោម ផៃ** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន។

សិក្ខាសាលានេះបានរៀបចំឡើងនៅ ខេត្តកំពត ដោយអគ្គលេខាធិការដ្ឋាន អ.ស.ហ. ក្នុងគោលបំណងកំណត់ប្រភេទហានិភ័យសម្រាប់ការតាមដានឃ្លាំមើលហានិភ័យ និងភាពគំរាមកំហែងនានាក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

## វគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម"



១៥.កាលពីថ្ងៃសៅរ៍ ១៥កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម" វគ្គទី៦ រយៈពេល៦ថ្ងៃ នៅអគារ ៣៤៥។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម។ វគ្គបណ្តុះបណ្តាលនេះក៏មានការអញ្ជើញចូលរួមពី **កញ្ញា វីរៈ បូរមី** អ្នកគ្រប់គ្រងផ្នែកបណ្តុះបណ្តាល និងប្រឹក្សាយោបល់អាជីវកម្ម តំណាង **លោក សាយ សុខខេង** អគ្គនាយក ក្រុមហ៊ុនឌីអេហ្វស៊ី (DFC) ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រី នៃនិយ័តករគណនេយ្យនិងសវនកម្ម ក្នុងនោះផងដែរក៏មានការអញ្ជើញចូលរួមពីសិក្ខាកាមចំនួន៥០នាក់។

## កិច្ចប្រជុំនិងពិភាក្សាលើសេចក្តីព្រាងលិខិតបទដ្ឋាន




១៦.កាលពី ថ្ងៃចន្ទ ២ រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤ នៅអគារ ៣៤៥ និយ័តករគណនេយ្យនិងសវនកម្មបានរៀបចំកិច្ចប្រជុំនិងពិភាក្សាលើសេចក្តីព្រាងលិខិតបទដ្ឋានមួយចំនួនក្រោមអធិបតីភាព

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

ដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ លោក លោកស្រី អគ្គនាយករង និងមានការអញ្ជើញចូលរួមពី លោក លោកស្រី អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ នៃ ន.គ.ស.។ សេចក្តីព្រាងលិខិតបទដ្ឋានដែលបានពិភាក្សា រួមមាន៖ ១. សេចក្តីព្រាងអនុក្រឹត្យស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ២.សេចក្តីព្រាងប្រកាសស្តីពីកាតព្វកិច្ចដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ៣.សេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងគុណភាពសវនកម្មនិងការអះអាង។ កិច្ចប្រជុំនេះមានគោលបំណងដើម្បីពិនិត្យនិងពិភាក្សាលើអនុសាសន៍ស្របតាមស្មារតី នៃកិច្ចប្រជុំបច្ចេកទេសអង្គភាពក្រោមឱវាទ អ.ស.ហ. កាលពីថ្ងៃទី៤ ខែកក្កដា

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី “សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ”



១៧.កាលពីថ្ងៃអង្គារ ៣ រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា និយ័តករគណនេយ្យនិងសវនកម្ម ក្រោមការដឹកនាំរបស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្ត និងអនុលោមភាព និង **លោក ម៉ាច់ ដារ៉ា** អនុប្រធានការិយាល័យនីតិកម្មនិងដោះស្រាយវិវាទ បានចូលរួមជាមួយអគ្គនាយកដ្ឋានពន្ធដារ ក្នុងសិក្ខាសាលាផ្សព្វផ្សាយស្តីពី “សៀវភៅណែនាំស្តីពីបែបបទ និងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ” និង“សៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ” ។

## កិច្ចប្រជុំវេទិកាកិច្ចសហប្រតិបត្តិការស្តង់ដាគណនេយ្យជាតិ “ខ្សែក្រវ៉ាត់មួយ ផ្លូវមួយ” លើកទី៦




១៨.កាលពីថ្ងៃអង្គារ ៣ រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋាន បានដឹកនាំមន្ត្រីនៃនាយកដ្ឋានបច្ចេកទេសចូលរួមកិច្ចប្រជុំវេទិកាកិច្ចសហប្រតិបត្តិការស្តង់ដាគណនេយ្យជាតិ “ខ្សែក្រវ៉ាត់មួយ ផ្លូវមួយ” លើកទី៦ ដែលបានរៀបចំឡើងដោយក្រសួងហិរញ្ញវត្ថុ នៃសាធារណរដ្ឋប្រជាមានិតចិន តាមប្រព័ន្ធអនឡាញ

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

Zoom។ វេទិកាកិច្ចសហប្រតិបត្តិការស្តង់ដាគណនេយ្យជាតិ “ខ្សែក្រវ៉ាត់មួយ ផ្លូវមួយ” លើកទី៦ នេះប្រព្រឹត្តឡើងរយៈពេល ៤ថ្ងៃ ចាប់ពីថ្ងៃទី២៣-២៦ ខែកក្កដា ឆ្នាំ២០២៤។

## ការប្រឡងប្រជែងជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា របស់និយ័តករគណនេយ្យនិងសវនកម្ម



១៩.កាលពីថ្ងៃពុធ ៤ រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំការប្រឡងប្រជែងលើវិញ្ញាសាសម្ភាសន៍ជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា ចំនួន៥នាក់ ឱ្យចូលបម្រើការងារនៅនិយ័តករគណនេយ្យនិងសវនកម្ម ដែលប្រព្រឹត្តទៅនៅបន្ទប់ប្រជុំ ន.គ.ស. ទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាព **លោក ជា ចាន់ថា** អគ្គនាយករង និងជាអនុប្រធាន អនុគណៈកម្មការសម្ភាសន៍ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាប្រធានអនុគណៈកម្មការសម្ភាសន៍ អមដោយ លោក លោកស្រី ជាសមាជិកនៃអនុគណៈកម្មការសម្ភាសន៍។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "លទ្ធផលនៃការចុះការត្រួតពិនិត្យគុណភាពសវនកម្មសម្រាប់ឆ្នាំ២០២៣ និងទិសដៅការងារបន្តលើកម្មវិធីត្រួតពិនិត្យគុណភាពសវនកម្ម"



២០.កាលពីថ្ងៃព្រហស្បតិ៍ ៥ រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ នៅអគារ 345 **លោក ជេន ផាត** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ នៃនាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម បានដឹកនាំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "លទ្ធផលនៃការចុះការត្រួតពិនិត្យគុណភាពសវនកម្មសម្រាប់ឆ្នាំ២០២៣ និងទិសដៅការងារបន្តលើកម្មវិធីត្រួតពិនិត្យគុណភាពសវនកម្ម" ដោយមានការចូលរួមពីនិយ័តករស្ថាប័នពាក់ព័ន្ធ និងសវនករដែលមកពីក្រុមហ៊ុនសវនកម្មចំនួន ៧៥ នាក់។ សិក្ខាសាលាផ្សព្វផ្សាយនេះត្រូវបានធ្វើឡើងក្នុងគោលបំណងផ្សព្វផ្សាយពីលទ្ធផលទូទៅនៃកម្មវិធីត្រួតពិនិត្យគុណភាពសវនកម្មកាលពីឆ្នាំ២០២៣ និងដើម្បីបង្កើតឱ្យមានជាវេទិកាពិភាក្សាលើបទពិសោធន៍ដែលបានអនុវត្តកន្លងមក និងការត្រៀមរៀបចំខ្លួនសម្រាប់ពេលអនាគតឱ្យធានាបាននូវគុណភាពសវនកម្មនៅកម្ពុជា។

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

## វគ្គបណ្តុះបណ្តាលស្តីពី មូលដ្ឋានគ្រឹះគណនេយ្យមុននឹងសិក្សាស្តង់ដាគណនេយ្យ”



២១.កាលពីថ្ងៃសុក្រ ៦រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤ **និយ័តករគណនេយ្យនិងសវនកម្ម** បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី **មូលដ្ឋានគ្រឹះគណនេយ្យ មុននឹងសិក្សាស្តង់ដាគណនេយ្យ**” រយៈពេល៣ថ្ងៃ នៅអគារ ៣៤៥។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាព **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ចារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម។ វគ្គបណ្តុះបណ្តាលនេះក៏មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម ម្ចាស់សហគ្រាស និងអ្នកដែលមានការទទួលខុសត្រូវលើកិច្ចការគណនេយ្យនិងហិរញ្ញវត្ថុចំនួន៣៣នាក់។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងនៅក្នុងគោលដៅដើម្បីបញ្ជ្រាបការយល់ដឹងអំពីមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្តោតទៅលើផ្នែកសំខាន់ៗដែលមូលដ្ឋានមុននឹងឈានទៅសិក្សាវគ្គស៊ីជម្រៅគឺវគ្គស្តង់ដារបាយការណ៍ទាក់ទងនិងហិរញ្ញវត្ថុអន្តរជាតិកម្ពុជា សម្រាប់សហគ្រាសធុន និងមធ្យម (CIFRS For SMEs) និងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរកម្ពុជា(CIFRS)។

## កិច្ចប្រជុំពិភាក្សាអំពី "ការរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល (Train-the-Trainer Program) សម្រាប់ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា" តាមប្រព័ន្ធអនឡាញ




© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

២២.កាលពីថ្ងៃសុក្រ ៦ រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី នាន បូនី** អគ្គនាយករងនៃ អមដោយ **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស និងមន្រ្តីជំនាញនៃនាយកដ្ឋានបច្ចេកទេស បានដឹកនាំកិច្ចប្រជុំពិភាក្សាអំពី "ការរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល (Train-the-Trainer Program) សម្រាប់ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា" តាមប្រព័ន្ធអនឡាញ Zoom ជាមួយតំណាងអគ្គនាយកដ្ឋានរតនាគារជាតិ និងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កិច្ចប្រជុំកម្រិតបច្ចេកទេសរវាងក្រុមការងារអន្តរក្រសួង និងតំណាងក្រុមហ៊ុនឯកជន



២៣. កាលពីថ្ងៃ៤-៦ រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤-២៦ខែកក្កដា ឆ្នាំ២០២៤ **លោកស្រី នាន បូនី** អគ្គនាយករង នៃនិយ័តករគណនេយ្យនិងសវនកម្ម តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី ថោ សេដ្ឋចាន់លីដា** អនុប្រធាននាយកដ្ឋាន បានអញ្ជើញចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសរវាងក្រុមការងារអន្តរក្រសួង និងតំណាងក្រុមហ៊ុនឯកជន ដើម្បីពិភាក្សាលើកិច្ចការពាក់ព័ន្ធនឹងមណ្ឌលហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំងជាប្រធានក្រុមការងារមណ្ឌលហិរញ្ញវត្ថុ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាព និងវិស័យឯកជន ។

## វគ្គបណ្តុះបណ្តាលស្តីពី “ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ”



២៤.កាលពីថ្ងៃចន្ទ ៩រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៤ **និយ័តករគណនេយ្យនិងសវនកម្ម** បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី **“ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ”** រយៈពេល៣ថ្ងៃ នៅអាគារ ៣៤៥។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករងនៃនិយ័តករគណនេយ្យនិងសវនកម្ម និង**លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងវត្តមានរបស់សិក្ខាកាមសរុបចំនួន ៤៦នាក់។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងនៅក្នុងគោលដៅបញ្ជ្រាបការយល់ដឹង និងសិក្សាលម្អិតលើលក្ខខណ្ឌតម្រូវនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ។

## កម្មវិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការ ជំរុញការផ្សព្វផ្សាយសម្រាប់ការអភិវឌ្ឍន៍វិស័យមូលបត្រនៅកម្ពុជា



២៥.កាលពីថ្ងៃចន្ទ ៩ រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែកក្កដា គ.ស. ២០២៤ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក**នៃនិយ័តករគណនេយ្យនិងសវនកម្ម បានអញ្ជើញចូលរួមកម្មវិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការ ជំរុញការផ្សព្វផ្សាយសម្រាប់ការអភិវឌ្ឍន៍វិស័យមូលបត្រនៅកម្ពុជា នៅទីស្តីការនិយ័តករមូលបត្រកម្ពុជា ។

## កិច្ចប្រជុំក្រុមការងារមណ្ឌលហិរញ្ញវត្ថុ ដើម្បីពិភាក្សាលើកិច្ចការពាក់ព័ន្ធនឹងមណ្ឌលហិរញ្ញវត្ថុ



២៦.កាលពីថ្ងៃពុធ ១១រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង នៃនិយ័តករគណនេយ្យនិងសវនកម្ម និង **លោកស្រី ថោ សេដ្ឋចាន់លីដា** អនុប្រធាននាយកដ្ឋាន បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារមណ្ឌលហិរញ្ញវត្ថុ ដើម្បីពិភាក្សាលើកិច្ចការពាក់ព័ន្ធនឹងមណ្ឌលហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំងជាប្រធានក្រុមការងារមណ្ឌលហិរញ្ញវត្ថុ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាព ។

រៀបចំដោយ÷**លោក ឡាយ វិចិត្រ**
សម្របសម្រួលអត្ថបទ÷**កញ្ញា សុខ ណារី**

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម